ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩២០៣ សហវ-សវផ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១

**គោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ លោក លោកស្រី**
**ជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាព ក្រោមចំណុះក្រសួងសេដ្ឋកិច្ច**
**និងហិរញ្ញវត្ថុនៅថ្នាក់កណ្តាលនិងតាមខេត្ត-រាជធានី**

**កម្មវត្ថុ** ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១២ ។

**យោង**
- ព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ព្រះរាជក្រមលេខ នស /រកម/ ១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០១១
- អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៤០ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- អនុក្រឹត្យលេខ ១៣៤ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ៤០៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារក្រមសីលធម៌សំរាប់សវនករផ្ទៃក្នុង និងស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង
- ប្រកាសលេខ ១១០៩ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_abm@yhoo.com

- សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- លិខិតលេខ ១៦៣៨ សហវ.សជក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ស្តីពីផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល ២០១១-២០១៣
- សារាចរណែនាំលេខ ១២ សរណន ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- ផ្អែកតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមប្រតិភូ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពនានាក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជ្រាបថា អនុលោមតាមផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល ២០១១-២០១៣ និងក្នុងគោលបំណងបន្តពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលការងារនៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនៅថ្នាក់កណ្តាល និងតាមខេត្ត-រាជធានីឱ្យបានប្រសើរឡើងមួយកំរិតទៀត ពិសេសធានាបាននូវនិរន្តរភាពនៃការឈានឡើងនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចជាបន្តរក្សានូវភាពជឿទុកចិត្តបាននៃថវិកា និងការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុជាជំហានៗ ដែលជាគន្លឹះរួមចំណែកគាំទ្រដល់ការអនុវត្ត " **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២** " របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំឱ្យនាយកដ្ឋានសវនកម្មផ្ទៃក្នុង រៀបចំផែនការសវនកម្មប្រចាំឆ្នាំ ២០១២ ឱ្យកាន់តែខិតទៅរកកំរិតស្តង់ដារអន្តរជាតិ ជាក់ស្តែង និងបញ្ចូលនូវការប្រែប្រួលថ្មីៗ ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និងគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ។

ជាលទ្ធផល ផែនការសវនកម្មប្រចាំឆ្នាំ ២០១២ នេះ ត្រូវបានរៀបចំឡើងផ្អែកលើផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំរំកិល ២០១១-២០១៣ ដែលបានប្រើប្រាស់ " **អភិក្រមផ្អែកលើដំណើរការមានហានិភ័យ** " (Risk Based Process Focused Approach) ជាមួយនឹងការកែតំរូវមួយចំនួន ក្នុងការកំណត់វិសាលភាពសវនកម្មទៅតាមកំរិត និងប្រភេទហានិភ័យថ្មីៗនៃដំណើរការនីមួយៗ ដែលជាលទ្ធផលនៃការវិវឌ្ឍថ្មីៗ ពីការដ្ឋានកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអគ្គ-នាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ព្រមទាំងគិតគូរដល់គោលដៅអាទិភាពរបស់រាជរដ្ឋា-ភិបាលបានកំណត់ ជាមួយពេលវេលា បទពិសោធន៍ និងសមត្ថភាព លទ្ធភាពរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងផ្ទាល់ ដោយលៃយ៉ាងណាធ្វើឱ្យផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១២ កាន់តែមានភាពជាក់ស្តែង អាចអនុវត្តបាន ហើយបំរើដល់គោលបំណងដូចបានរំលឹកខាងលើ ។ អនុលោមតាមគោលបំណង នីតិវិធី និងការគិតគូរនេះ មានអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពសំខាន់ៗថ្នាក់កណ្តាលចំនួន ១២ និងតាមខេត្ត-រាជធានីទាំង ២៤ ត្រូវបានចាត់បញ្ចូល

ក្នុងផែនការសវនកម្មផ្ទៃក្នុងសំរាប់ឆ្នាំ ២០១២ (សូមពិនិត្យផែនការសវនកម្មកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១២ ដូចជូនភ្ជាប់) ។

សវនកម្មលើអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពនៅថ្នាក់កណ្ដាល និងតាមខេត្ត-រាជធានី នឹងផ្ដោតទៅលើកម្មវត្ថុសំខាន់ៗ ដូចជាៈ ទៅលើគុណភាព ភាពគ្រប់គ្រាន់ សង្គតិភាព សុពលភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងព្រមទាំងភាពជាប់លាប់នៃការប្រើប្រាស់ ភាពអនុលោមតាមផែនការ នីតិវិធី និងបទដ្ឋានច្បាប់ពិសេសវិន័យ ១១ ប្រការ ភាពត្រឹមត្រូវនិងទាន់ពេលនៃការកត់ត្រាបញ្ជិកាគណនេយ្យ ប្រសិទ្ធភាពប្រតិបត្តិការ និងភាពជឿទុកចិត្តបាននៃរបាយការណ៍ ភាពត្រឹមត្រូវរបស់វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងនិងរក្សាសុវត្ថិភាពនៃទ្រព្យសម្បត្តិ ភាពសន្សំសំចៃក្នុងការប្រើប្រាស់ធនធានសាធារណៈ កិច្ចសហប្រតិបត្តិការរវាងអង្គភាព គុណភាពនៃការពង្រឹងសមត្ថភាព និងការគ្រប់គ្រងមុខងារមន្ត្រីរាជការ ។

ថ្នាក់ដឹកនាំសវនដ្ឋាន (អង្គភាពរងសវនកម្ម) និងមជ្ឈដ្ឋានពាក់ព័ន្ធ ត្រូវផ្ដល់ការយកចិត្តទុកដាក់និងកិច្ចសហការល្អដល់សវនករ ដើម្បីសំរេចបាននូវកម្មវត្ថុសវនកម្មខាងលើ ក៏ដូចជាការផ្ដល់នូវសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យ និងចូលដល់ផ្នែកផ្សេងៗនៃអង្គភាព សកម្មភាពនានា ឯកសារពាក់ព័ន្ធ លិខិតបទដ្ឋានច្បាប់ បញ្ជិកា ស្ថិតិទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ និងមន្ត្រីរាជការ ។ ទន្ទឹមនឹងនេះ សវនករត្រូវបំពេញការងារសវនកម្មដោយឯករាជ្យ មិនលំអៀង ស្របតាមស្តង់ដារ និងក្រមសីលធម៌វិជ្ជាជីវៈនៃសវនករផ្ទៃក្នុង ដើម្បីផ្ដល់នូវអនុសាសន៍កែលំអ សំដៅបន្ថែមតំលៃជួយឱ្យអង្គភាពសំរេចនូវគោលដៅដែលបានកំណត់ ។ ការតាមដានទៅលើការកែលំអតាមអនុសាសន៍នឹងត្រូវធ្វើក្នុងរយៈពេល ៦ ខែក្រោយសវនកម្មបានបញ្ចប់ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវចុះធ្វើសវនកម្មទៅតាមផែនការសវនកម្មផ្ទៃក្នុង ប្រចាំឆ្នាំ ២០១២ នេះ តាមករណីចាំបាច់លើមូលដ្ឋានបណ្ដឹង សំណូមពររបស់អង្គភាពក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមការចង្អុលបង្ហាញរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយជូននិងមិនជូនដំណឹងជាមុន ។

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តមប្រតិភូ ឯកឧត្តម លោកជំទាវ លោក លោកស្រីជ្រាប និងចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ ២០១២ នេះ ឱ្យបានសំរេចជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

*ចំលងជូនៈ*

- អាជ្ញាធរសវនកម្មជាតិ
- សាលារាជធានីភ្នំពេញ និងសាលាខេត្ត
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ